# ភូមិថ្លុកត្រាច និងភូមិអន្លង់ជ្រៃដែលកាត់ឲ្យយួន






# អ្នកកាត់ដីឲ្យគេតិចឬច្រើនជាជនក្បត់ជាតិ




## ភាពអស្វារ្យរបស់មេដឹកនាំគឺការហ៊ានទទួលខុសត្រូវ តើហ៊ុន សែន មានសេចក្តីក្លា ហាន ទទួលខុសត្រូវទេ?

មានអ្នកកាន់ជើង ហ៊ុន សែនខ្លះនិយាយថា ហ៊ុនសែន មានផលវិបាកបានធ្វើបែបនេះ។ តែបើយើងមានផលវិបាក ដឹកនាំស្រុកមិនបាន មិនហ៊ានដោះស្រាយបញ្ហាជាមួយយួនមែន សូម ចុះចេញពីតំ ណែង ទៅ ស្រុកខ្មែរមិនខ្វះទេ  មនុស្សមានសមត្ថភាពដឹកនាំប្រទេស។មានអ្នកខ្លះក៏ចោទសួរដែរថាតើមានសង្គ្រាមទេបើយើងកាពារទឹកដីយើងជាមួយយួនឈ្លានពាន? ខ្ញុំជឿជាក់ថា មិនអាចទេ បើខ្លាំងណាស់ មានត្រឹមការប៉ះទង្គិចបន្តិចបន្តួចដូច សៀមតែ ប៉ុណ្ណោះព្រោះសម័យនេះ មិនអាចទៅរួចទេ បើយើងប្រើច្បាប់មកដោះស្រាយជាមូលដ្ឋាន។ ជាពិសេសខ្មែរនិងយួន រួមទាំងសៀម ផងប្រទេសទាំងពីរនេះជាម្ចាស់ ហត្ថលេខីនៃ កិច្ចព្រម ព្រៀងទីក្រុងប៉ារីស ១៩៩១។ ដូច្នេះពួក គេពិតជាមិនហ៊ានបំពានយើងទេ បើយើង ហ៊ានតវ៉ាតាម ច្បាប់ តែបើយើងតវ៉ាតាមអាវុធ ពួកគេនឹងមិនខ្លាចយើងឡើយ។

**បញ្ជាក់៖** ជនរួមជាតិទាំងអស់ត្រូវចាំថា យួនពេលវាដោះស្រាយព្រំដែនជាមួយចិន វាមិនត្រឹមតែយកមនុស្សចាស់ៗ មកធ្វើជាសំអាងប្រាប់ចិនថាពួកគេធ្លាប់រស់នៅទីនេះទេ សូម្បីតែកូនក្មេងធ្លាប់ទៅលេងទីនោះក៏វាយកមកជាសំអាង បន្ថែមទៅលើច្បាប់ដែរ ហើយថែមទាំងធ្វើកំណាយរកវត្ថុតាងចាស់ៗមកបង្ហាញថាជាដីវាជាកន្លែងប្រជាជនវាធ្លាប់រស់នៅទៀតយកទៅតទល់ជាមួយចិន លើសពីនេះវាថែមទាំងលើក យកមកតាំងពីរឿង ព្រេងឡើងទៅ។

ចុះខ្មែរ ? តើពួកយួនទាំងនោះពីដើមមកទឹកដីវានៅទីនោះមែនទេ? ហេតុអីចាំបាច់ឆ្ងល់ម្លេះមិនចាំបាច់និយាយដល់ ប្រវត្តិ សាស្ត្រទេគ្រាន់តែនិយាយពីភាពជាក់ស្តែងគឺមនុស្សរស់នៅទីនោះរាប់រយគ្រួសារ តាំងពីដូនតាមកជាខ្មែរ ម៉េច បានជាទៅដីយួនកើត?